ខ) A ជាចំណុចនៅលើខ្សែកោង C ដែលមានអាប់ស៊ីស 0 ។ កំណត់សមីការបន្ទាត់ប៉ះខ្សែកោង C ត្រង់ចំណុច A ។

គ) បង្ហាញថាសមីការ $f(x) = 0$ មានចម្លើយតែមួយគត់ដែលគេតាងដោយ β នៅក្នុងចន្លោះ $[-1, 0]$ ។

ដំណោះស្រាយ

ក្រសួងអប់រំ យុវជន និងកីឡា លេខបន្ទប់៖________

វិញ្ញាសាគណិតវិទ្យា នៃវិញ្ញាសាឆ្នាំ២០០២-២០២៥ លេខតុ៖________

សម័យប្រឡង៖________ មណ្ឌលប្រឡង៖________

ហត្ថលេខាអនុរក្ស៖ នាមត្រកូល និងនាមខ្លួន៖________

ថ្ងៃខែឆ្នាំកំណើត៖________

វិញ្ញាសាទី ១៤ ហត្ថលេខា៖________ អក្សរសម្ងាត់

• បេក្ខជនមិនត្រូវធ្វើសញ្ញាសម្គាល់អ្វីមួយនៅលើក្រដាស់ប្រឡងឡើយ។ ក្រដាស់ប្រឡងណាដែលមានសម្គាល់នឹងត្រូវបានពិន្ទុសូន្យ។

• បេក្ខជនមិនត្រូវចម្លងប្រធានវិញ្ញាសាដាក់លើក្រដាស់ប្រឡងជាដាច់ខាត។

វិញ្ញាសាទី១៤៖ គណិតវិទ្យា (ថ្នាក់វិទ្យាសាស្ត្រ) អក្សរសម្ងាត់

រយៈពេល៖ ១៥០នាទី

ប្រធាន៖

I (២០ពិន្ទុ) គណនាលីមីតខាងក្រោម៖

ក) $\lim\limits_{x\to 2}\dfrac{x^3-2x^2+x-2}{x-2}$

ខ) $\lim\limits_{x\to \frac{\pi}{2}}\dfrac{\sin^2 x-1}{1-\sin x}$

គ) $\lim\limits_{x\to +\infty}\left(\sqrt{x^2+2x}-x\right)$

ឃ) $\lim\limits_{x\to 0}\dfrac{(e^{-2x}+e^{2x})\sin^2(2x)}{4x^2}$

ង) $\lim\limits_{x\to +\infty}\left(\ln(x+3)-\ln x-\dfrac{3}{x+3}+\dfrac{1}{2}\right)$

II (២០ពិន្ទុ)

១) គេមានចំនួនកុំផ្លិច $z_1=\sqrt{3},\ z_2=-i\sqrt{3},\ z_3=+i\sqrt{3}$ ។

ក) គណនា $z_1+z_2,\quad z_1+z_3,\quad (z_1+z_2)(z_1+z_3)$ ។

ខ) កំណត់ម៉ូឌុល និងអាគុយម៉ង់នៃ $z_1+z_2,\ \ z_1+z_3,\ \ \left(\dfrac{z_1+z_3}{z_1+z_2}\right)^2$ ។

២) កំណត់ i^n ចំពោះតម្លៃនៃចំនួនគត់រ៉ឺឡាទីប $n\geq 1$ ។ ទាញរកតម្លៃ $i^{2025}-i^{2024}$ ។

III (១៥ពិន្ទុ) ក្នុងថ្នាក់រៀនមួយមានសិស្សអាស៊ី ៥ នាក់ សិស្សអាហ្វ្រិក ៣ នាក់ និងសិស្សអឺរ៉ុប ២ នាក់។ គេរៀបចំសិស្សជាក្រុមស្ម័យសិក្សាក្នុងមួយក្រុមមានសិស្ស ៣ នាក់ដោយចៃដន្យ។ រកប្រូបាបនៃព្រឹត្តិការណ៍ដូចខាងក្រោម៖

ក) «យ៉ាងតិចមានសិស្ស ២ នាក់ ជាសិស្សអាស៊ី»។

ខ) «យ៉ាងតិចមានសិស្ស ២ នាក់ ជាសិស្សអាហ្វ្រិក»។

គ) «មានសិស្សម្នាក់ក្នុងមួយទ្វីប»។

IV (៣៥ពិន្ទុ) គេមានអនុគមន៍ f កំណត់លើ $I=]0,+\infty[$ ដោយ $f(x)=\dfrac{x+2\ln x}{x^3}$ ។

១) h ជាអនុគមន៍កំណត់លើ I ដោយ $h(x)=-2x+2-6\ln x$ ។

គណនា $h(1)$ និងសិក្សាអថេរភាពនៃ $h(x)$ ដោយគេមិនតម្រូវឲ្យគណនាលីមីតនៃ $h(x)$ ត្រង់ 0 និងត្រង់ $+\infty$ ឡើយ។

២) ក) គណនាលីមីតនៃ $f(x)$ ត្រង់ 0 និងត្រង់ $+\infty$ ។

ខ) គណនាដេរីវេ $f'(x)$ នៃអនុគមន៍ $f(x)$ ។

គ) បង្ហាញថានៅលើ $I,\ \ f'(x)$ មានសញ្ញាដូច $h(x)$ ។

ឃ) ទាញយកអថេរភាពនៃ $f(x)$ លើ I និងសង់ក្រាប C នៃ $f(x)$ នៅលើប្លង់ប្រដាប់ដោយតម្រុយអរតូណរម៉ាល់ $\left(O,\ \vec{i},\ \vec{j}\right)$។

V (១៥ពិន្ទុ) គេមានសមីការឌីផេរ៉ង់ស្យែល $(E):\quad y''+9y=x^2+x-2$ ។

១) រកអនុគមន៍ $f_1(x)=ax^2+bx+c$ ជាចម្លើយរបស់សមីការ (E) ។

២) បង្ហាញថាបើ $f(x)$ ជាចម្លើយនៃសមីការ (E) នោះ៖ $g(x)=f(x)-f_1(x)$ ជាចម្លើយនៃសមីការ $y''+9y=0$ ។

VI (២០ពិន្ទុ)

១ ក្នុងតម្រុយអរតូណរម៉ាល់មានទិសដៅវិជ្ជមាន $\left(O, \vec{i}, \vec{j}, \vec{k}\right)$ គេមានចំណុច $A(3,3,2),\ B(5,-1,1),\ C(4,2,2),\ D(2,6,3)$។ បង្ហាញថា $ABCD$ ជាប្រលេឡូក្រាម រួចរកផ្ទៃក្រឡាប្រលេឡូក្រាមនេះ។

២ រកសមីការប៉ារ៉ាម៉ែតនៃបន្ទាត់ ដែលកាត់តាមចំណុច $A(3,3,2)$ និង $B(5,-1,1)$ ។

៣ រកសមីការប្លង់ ដែលកាត់តាមចំណុច $A(3,3,2),\ B(5,-1,1),\ D(2,6,3)$ ។

ដំណោះស្រាយ

ក្រសួងអប់រំ យុវជន និងកីឡា លេខបន្ទប់៖__________

វិញ្ញាសាគណិតវិទ្យា នឹងវិញ្ញាសាឆ្នាំ២០០២-២០២៥ លេខតុ៖__________

សម័យប្រឡង៖______________________ មណ្ឌលប្រឡង៖______________________

ហត្ថលេខាអនុរក្ស នាមត្រកូល និងនាមខ្លួន៖______________________

ថ្ងៃខែឆ្នាំកំណើត៖______________________

វិញ្ញាសាទី ១៥ ហត្ថលេខា៖______________________ | អក្សរសម្ងាត់ |

- បេក្ខជនមិនត្រូវធ្វើសញ្ញាសម្គាល់អ្វីមួយនៅលើក្រដាសប្រឡងឡើយ។ ក្រដាសប្រឡងណាដែលមានសម្គាល់នឹងត្រូវបានពិន្ទុសូន្យ។
- បេក្ខជនមិនត្រូវចម្លងប្រធានវិញ្ញាសាដាក់លើក្រដាសប្រឡងជាដាច់ខាត។

✂ -

វិញ្ញាសាទី១៥៖ គណិតវិទ្យា (ថ្នាក់វិទ្យាសាស្ត្រ) | អក្សរសម្ងាត់ |

រយៈពេល៖ ១៥០នាទី

ប្រធាន៖

I (១៥ពិន្ទុ) គេមានចំនួនកុំផ្លិច $z_1 = -\sqrt{3} + i$ និង $z_2 = \sqrt{3} - i$ ។

① គណនា $z_1 + z_2,\ \ z_1 - z_2,\ \ z_1 \times z_2$ ។

② សរសេរជាទម្រង់ត្រីកោណមាត្រនៃចំនួនកុំផ្លិច $z_1 - z_2,\ \ z_1 \times z_2$ ។

II (១៥ពិន្ទុ) គណនាលីមីត៖

ក. $\lim\limits_{x\to 3} \dfrac{x^3 - 27}{\sqrt{x+1} - 2}$ ខ. $\lim\limits_{x\to 0} \dfrac{1 - \cos 2x}{x \sin x}$ គ. $\lim\limits_{x\to 0} \dfrac{2\sin 4x}{x}$

III (១០ពិន្ទុ) ក្នុងស្បោងមួយមានប៊ូលពណ៌ស ៥ ប៊ូលពណ៌ខៀវ ៣ និងប៊ូលពណ៌ក្រហម ២ ។ គេចាប់យកប៊ូលម្តង ៣ ក្នុងពេលតែមួយចេញពីស្បោងដោយចៃដន្យ។ គេសន្និដ្ឋានថាប្រូបាបដែលចាប់បានប៊ូលនីមួយៗជាសមប្រូបាប។
គណនាប្រូបាបនៃព្រឹត្តិការណ៍ខាងក្រោម៖

ក. A : «យ៉ាងតិចមានប៊ូលពីរពណ៌ខៀវ»

ខ. B : «ប៊ូលទាំងបីមានពណ៌ខុសៗគ្នា»

IV (១៥ពិន្ទុ)

ក. គណនាអាំងតេក្រាល $I = \displaystyle\int_1^2 \left(\frac{x^2}{2} - \frac{x}{3} + 2\right) dx$ ។

ខ. គេមានអនុគមន៍ $f(x) = -\dfrac{3-x}{(x-2)^2}$ ។ បង្ហាញថា $f(x) = -\dfrac{1}{(x-2)^2} + \dfrac{1}{x-2}$ ។ គណនា $K = \displaystyle\int_0^1 f(x)dx$ ។

V (២៥ពិន្ទុ)

ក. គេមានវ៉ិចទ័រ $\vec{u} = 2\vec{i} - \vec{j} + \vec{k},\ \ \vec{v} = \vec{i} + 2\vec{j} - \vec{k},\ \ \vec{w} = -\vec{i} + \vec{j} + 2\vec{k}$ ។
រកវ៉ិចទ័រ ៖ ក. $\vec{u} + \vec{v}$ ខ. $\vec{w} \times \vec{u}$ គ. $\vec{w} \times \vec{v}$ ។

ខ. រកសមីការស្តង់ដានៃអេលីប ដែលមានកំពូលមួយមានកូអរដោនេ $(2,0)$ និងចំណុចកំពូលពីរមានកូអរដោនេ $(-4,0)$ និង $(4,0)$។ សង់អេលីបនេះ។

VI (១០ពិន្ទុ) គេមានសមីការឌីផេរ៉ង់ស្យែល $(E):\ y' + 3y = 3\dfrac{e^{-2x}}{1+3e^{x}}$ ។

① ផ្ទៀងផ្ទាត់ថាអនុគមន៍ f ដែល $f(x) = e^{-3x}\ln(1+3e^x)$ ជាចម្លើយនៃ (E) ។

② បង្ហាញថាអនុគមន៍φ ជាចម្លើយនៃ(E) លុះត្រាតែ$(\varphi - f)$ ជាចម្លើយនៃសមីការ(E') : $y' + 3y = 0$។

VII (៣៥ពិន្ទុ)

A : គេមានអនុគមន៍ g កំណត់លើ $(0,+\infty)$ ដោយ $g(x) = x^2 + \ln x$ ។

①ក. បង្ហាញថា g ជាអនុគមន៍កើនដាច់ខាតលើ $(0,+\infty)$ ។

ខ. គណនា $g(1)$ ។

២ ក ទាញលទ្ធផលពីសំណួរទី១បញ្ជាក់ថា៖ បើ $x \geq 1$ នោះ $x^2 + \ln x \geq 1$ និងបើ $0 < x \leq 1$ នោះ $x^2 + \ln x \leq 1$។

ខ កំណត់សញ្ញានៃកន្សោម $x^2 + \ln x - 1$ កាលណា x នៅលើចន្លោះ $(0, +\infty)$ ។

B : គេមានអនុគមន៍ f កំណត់លើ $(0, +\infty)$ ដោយ $f(x) = x - 3 - \dfrac{\ln x}{x}$ និងតាងដោយC ជាក្រាបរបស់វាក្នុងតម្រុយអរតូណរម៉ាល់ $\left(O, \vec{i}, \vec{j}\right)$ ។

១ សិក្សាលីមីតនៃអនុគមន៍ f ត្រង់ 0 និង $+\infty$ (យើងដឹងថា $\lim\limits_{x \to +\infty} \dfrac{\ln x}{x} = 0$)។

២ បង្ហាញថាដេរីវេនៃអនុគមន៍ f គឺ $f'(x) = \dfrac{x^2 + \ln x - 1}{x^2}$ ។

៣ ប្រើលទ្ធផលនៃសំណួរខាងលើ សិក្សាសញ្ញានៃ $f'(x)$ និងសង់តារាងអថេរភាពនៃអនុគមន៍ f លើ$(0, +\infty)$។

៤ ក បង្ហាញថាបន្ទាត់ Δ មានសមីការ $y = x - 3$ ជាអាស៊ីមតូតទៅនឹងក្រាប C ត្រង់ $+\infty$។

ខ សិក្សាទីតាំង C ធៀបនឹង Δ និងបញ្ជាក់កូអរដោនេនៃចំណុចប្រសព្វ I រវាងក្រាប C និង Δ។

សង់បន្ទាត់ Δ និងក្រាប C។

ដំណោះស្រាយ

ក្រសួងអប់រំ យុវជន និងកីឡា លេខបន្ទប់៖________

វិញ្ញាសាគណិតវិទ្យា នឹងវិញ្ញាសាឆ្នាំ២០០២-២០២៥ លេខតុ៖________

សម័យប្រឡង៖________________ មណ្ឌលប្រឡង៖________________

ហត្ថលេខាអនុរក្ស៖ នាមត្រកូល និងនាមខ្លួន៖________________

ថ្ងៃខែឆ្នាំកំណើត៖________________

វិញ្ញាសាទី ១៦ ហត្ថលេខា៖________________ | អក្សរសម្ងាត់ |

- បេក្ខជនមិនត្រូវធ្វើសញ្ញាសម្គាល់អ្វីមួយនៅលើក្រដាល់ប្រឡងឡើយ។ ក្រដាស់ប្រឡងណាដែលមានសម្គាល់នឹងត្រូវបានពិន្ទុសូន្យ។
- បេក្ខជនមិនត្រូវចម្លងប្រធានវិញ្ញាសាដាក់លើក្រដាស់ប្រឡងជាដាច់ខាត។

✂ -

វិញ្ញាសាទី១៦៖ គណិតវិទ្យា (ថ្នាក់វិទ្យាសាស្ត្រ) | អក្សរសម្ងាត់ |

រយៈពេល៖ ១៥០នាទី

ប្រធាន៖

I (១៥ពិន្ទុ) គណនាលីមីត៖

ក. $\lim\limits_{x\to 2}\dfrac{x^2-4}{x^2-x-2}$ ខ. $\lim\limits_{x\to 4}\dfrac{\sqrt{x+5}-3}{x^2-16}$ គ. $\lim\limits_{x\to 0}\dfrac{3\sin 4x}{x}$

II (១៥ពិន្ទុ) គេមានចំនួនកុំផ្លិច $z_1=2-i$; $z_2=-1+i\left(1+\sqrt{3}\right)$ និង $z_3=\dfrac{1}{2}$ ។

គណនា z_1+z_2 , $(z_1+z_2)\times z_3$ ។

សរសេរជាទម្រង់ត្រីកោណមាត្រនៃចំនួនកុំផ្លិច $Z=(z_1+z_2)\times z_3$ ។ ទាញរកតម្លៃនៃ Z^3 ។

III (១៥ពិន្ទុ) គណនាអាំងតេក្រាល $I=\displaystyle\int_0^3\left(3x^2-2x+1\right)dx$, $J=\displaystyle\int_0^{\frac{\pi}{4}}\left(2\cos^2 x-1\right)dx$ ។

គេមាន f កំណត់លើ $\mathbb{R}^*$ ដោយ $f(x)=\dfrac{3x-2}{x^2}$ ។ បង្ហាញថា $f(x)=\dfrac{3}{x}-\dfrac{2}{x^2}$ ។

គណនា $K=\displaystyle\int_1^e f(x)dx$ ។ $(\ln e=1)$

IV (១០ពិន្ទុ) ក្នុងថង់មួយមានប៊ូល ១២ ដែលចែកជា ប៊ូលពណ៌បៃតងចំនួន ៥ និងគេសរសេរលើប៊ូលទាំង ៥ នេះតាមលេខរៀងពី ១ ដល់ ៥ រួចប៊ូលខៀវចំនួន ៤ និងគេសរសេរលើប៊ូលទាំង ៤ នេះតាមលេខរៀងពី ១ ដល់ ៤ ចុងក្រោយប៊ូលពណ៌ក្រហមចំនួន ៣ និងគេសរសេរលើប៊ូលទាំង ៣ នេះតាមលេខរៀងពី ១ ដល់ ៣ ។ គេចាប់យកប៊ូលមួយចេញពីក្នុងថង់ដោយចៃដន្យ។ រកប្រូបាបនៃព្រឹត្តិការណ៍ខាងក្រោម៖

ក. A : ប៊ូលដែលចាប់បានមានពណ៌បៃតង។

ខ. B : ប៊ូលដែលចាប់បានមានលេខគូ។

គ. C : ប៊ូលដែលចាប់បានមានពណ៌បៃតង និងលេខគូ។

V (២៥ពិន្ទុ)

១. គេមានសមីការ $9x^2+25y^2=225$ ។

ក. បង្ហាញថាសមីការនេះជាសមីការអេលីប។ រកប្រវែងអ័ក្សធំ, ប្រវែងអ័ក្សតូច និងកូអរដោនេនៃកំពូលទាំងពីរ។

ខ. សង់អេលីបនេះ។

២. នៅក្នុងលំហប្រដាប់ដោយតម្រុយអរតូណរម៉ាល់ $\left(O,\vec{i},\vec{j},\vec{k}\right)$ គេមានចំណុច $\mathrm{M}(1,2,3)$, $\mathrm{N}(2,4,5)$, $\mathrm{P}(5,5,6)$, $\mathrm{Q}(4,$
។

ក. រកវ៉ិចទ័រ $\overrightarrow{\mathrm{MN}}$, $\overrightarrow{\mathrm{QP}}$ ។

ខ. ទាញបង្ហាញថាចតុកោណ MNPQ ជាប្រលេឡូក្រាម។

VI (១០ពិន្ទុ)

ក. ដោះស្រាយសមីការឌីផេរ៉ង់ស្យែល (E) : $y''-4y'+3y=0$ ។

ខ. រកចម្លើយពិសេសមួយនៃសមីការឌីផេរ៉ង់ស្យែល (E) ដែល $y(0)=2,\ y'(0)=4$ ។

VII (៣៥ពិន្ទុ) គេឲ្យអនុគមន៍ f កំណត់លើ $\mathbb{R}$ ដោយ $f(x) = x + 3 - \dfrac{4e^x}{e^x + 2}$ ។ គេតាង C ជាក្រាបរបស់វានៅក្នុងប្លង់ប្រដាប់ដោយតម្រុយអរតូណរម៉ាល់ $\left(O, \vec{i}, \vec{j}\right)$ ។

១ ក. គណនាលីមីត f ត្រង់ $-\infty$ និង $+\infty$ ។

ខ. សិក្សាទីតាំងនៃក្រាប C ធៀបនឹងបន្ទាត់ d_1 ដែលមានសមីការ $y = x + 3$ ។

២ ក. ស្រាយបញ្ជាក់ថាចំពោះគ្រប់ចំនួនពិត x, $f'(x) = \left(\dfrac{e^x - 2}{e^x + 2}\right)^2$ ។

ខ. សិក្សាអថេរភាពនៃ f លើ $\mathbb{R}$ និង សង់តារាងអថេរភាពនៃ f ។

៣ ក. តើគេអាចថាយ៉ាងណាចំពោះបន្ទាត់ប៉ះ d_2 ទៅនឹងក្រាប C ត្រង់ចំណុច I ដែលមានអាប់ស៊ីស $\ln(2)$?

ខ. សិក្សាទីតាំងនៃក្រាប C ធៀបនឹងបន្ទាត់ប៉ះ d_2 ។

៤ ក. បង្ហាញថាបន្ទាត់ប៉ះ d_3 ទៅនឹងក្រាប C ត្រង់ចំណុចដែលមានអាប់ស៊ីសសូន្យមានសមីការ $y = \dfrac{1}{9}x + \dfrac{5}{3}$ ។

ខ. ដោយសន្មត់ថាចំនុច I ជាផ្ចិតឆ្លុះនៃក្រាប C និងក្នុងតម្លៃប្រហែលនៃ $\ln(2) \approx 0.7$ ។
ចូរសង់ក្រាប C និងបន្ទាត់ប៉ះ $d_1, d_2,\ d_3$ ។ (នៅក្នុងតម្រុយនេះមួយឯកតាស្មើ 2cm)

ដំណោះស្រាយ

ក្រសួងអប់រំ យុវជន និងកីឡា លេខបន្ទប់៖________

វិញ្ញាសាគណិតវិទ្យា នៃវិញ្ញាសាឆ្នាំ២០០២-២០២៥ លេខតុ៖________

សម័យប្រឡង៖________ មណ្ឌលប្រឡង៖________

ហត្ថលេខាអនុរក្ស៖ នាមត្រកូល និងនាមខ្លួន៖________

វិញ្ញាសាទី ១៧ ថ្ងៃខែឆ្នាំកំណើត៖________ **អក្សរសម្ងាត់**

ហត្ថលេខា៖________

• បេក្ខជនមិនត្រូវធ្វើសញ្ញាសម្គាល់អ្វីមួយនៅលើក្រដាស់ប្រឡងឡើយ។ ក្រដាស់ប្រឡងណាដែលមានសម្គាល់នឹងត្រូវបានពិន្ទុសូន្យ។

• បេក្ខជនមិនត្រូវចម្លងប្រធានវិញ្ញាសាដាក់លើក្រដាស់ប្រឡងជាដាច់ខាត។

វិញ្ញាសាទី១៧៖ គណិតវិទ្យា (ថ្នាក់វិទ្យាសាស្ត្រ) **អក្សរសម្ងាត់**

រយៈពេល៖ ១៥០នាទី

ប្រធាន៖

I (១៥ពិន្ទុ) គណនាលីមីត៖

ក $\lim_{x\to 1}\dfrac{1-x^2}{x^3-x^2+2x-2}$ ខ $\lim_{x\to 0}\dfrac{\sin 4x}{-2x}$ គ $\lim_{x\to 0}\dfrac{\sqrt{3+x}-\sqrt{3-x}}{\sin 2x}$

II (១០ពិន្ទុ) ក្នុងថ្នាក់រៀនមួយមានសិស្សពូកែចំនួន 12 នាក់ ដែលក្នុងនោះ 5 នាក់ជាសិស្សស្រី និង 7 នាក់ជាសិស្សប្រុស។ គេរៀបចំសិស្សជាក្រុមក្នុងមួយក្រុមមានសិស្ស 4 នាក់ ដោយចៃដន្យ យកទៅប្រកួតជាមួយក្រុមសិស្សនៃថ្នាក់ដទៃ។ រកប្រូបាបនៃព្រឹត្តិការណ៍ខាងក្រោម៖

ក A : "ក្រុមសិស្សដែលជ្រើសរើសបានសុទ្ធតែស្រី"

ខ B : "ក្រុមសិស្សដែលជ្រើសរើសបានសុទ្ធតែប្រុស"

គ C : "ក្រុមសិស្សដែលជ្រើសរើសបាន 50% ជាសិស្សប្រុស"

III (១៥ពិន្ទុ) គេមានចំនួនកុំផ្លិច $z_1=\sqrt{3}+i$ និង $z_2=4\left(\cos\dfrac{\pi}{3}-i\sin\dfrac{\pi}{3}\right)$ ។

ក សរសេរ z_1 ជាទម្រង់ត្រីកោណមាត្រ។

ខ រកម៉ូឌុល និងអាគុយម៉ង់នៃ z_1^3 ។

គ សរសេរផលគុណ $z_1\times z_2$ ជាទម្រង់ពីជគណិត។

IV (២៥ពិន្ទុ)

១ ក្នុងតម្រុយអរតូណរម៉ាល់ $\left(O,\vec{i},\vec{j},\vec{k}\right)$ គេមានចំណុច $\mathrm{A}(1,1,1)$, $\mathrm{B}(3,1,2)$, $\mathrm{C}(2,2,-1)$ និង $\mathrm{D}(0,6,3)$។

ក រកវ៉ិចទ័រ $\overrightarrow{AB},\ \overrightarrow{AC},\ \overrightarrow{AD},\ \overrightarrow{BC},\ \overrightarrow{BD},\ \overrightarrow{CD}$ ។

ខ គណនាប្រវែង AB, AC, AD, BD និង CD ។ ទាញបង្ហាញថាត្រីកោណ ABD និង ACD កែងត្រង់ A ។

២ គេមានសមីការ $16y^2-9x^2=144$ ។ បង្ហាញថាសមីការនេះជាសមីការអ៊ីពែបូល។ រកកូអរដោនេរបស់កំពូលទាំងពីរ និងកំណុំទាំងពីរនៃអ៊ីពែបូល។ រកសមីការអាស៊ីមតូតរបស់អ៊ីពែបូលនេះ និងសង់អ៊ីពែបូលនេះ។

V (១៥ពិន្ទុ) គណនាអាំងតេក្រាល៖

$\mathrm{I}=\int_1^2\left(3x^2-4x+1\right)dx;\qquad \mathrm{J}=\int_0^{\frac{\pi}{4}}(\cos 2x-\sin x)\,dx$ គណនាអាំងតេក្រាល៖ $\mathrm{K}=\int_0^1\dfrac{x^3+2x^2+2x+2}{x^2+1}$

ដើម្បីគណនា K យើងត្រូវបង្ហាញថា $\dfrac{x^3+2x^2+2x+2}{x^2+1}=x+2+\dfrac{x}{x^2+1}$ ។

VI (១០ពិន្ទុ)

ក ដោះស្រាយសមីការឌីផេរ៉ង់ស្យែល (E) : $y''-4y'+3y=0$

ខ រកចម្លើយពិសេសមួយនៃសមីការឌីផេរ៉ង់ស្យែល (E) ដែល $y(0)=2$ និង $y'(1)=e+3e^3$។

VII (៣៥ពិន្ទុ) គេមានអនុគមន៍ f កំណត់លើ $\mathbb{R}$ ដោយ $f(x)=2x+\dfrac{4-4e^x}{1+e^x}$ ។

គេតាងដោយ (C) ក្រាបរបស់វានៅក្នុងប្លង់ប្រដាប់ដោយតម្រុយអរតូណរម៉ាល់ $\left(O, \vec{i}, \vec{j}\right)$ ។

១ បង្ហាញថា $f(x) = 2x + 4 - \dfrac{8e^x}{1+e^x}$ និងគណនាលីមីតនៃ f ត្រង់ $-\infty$។
ស្រាយបំភ្លឺថាបន្ទាត់ (d_1) ដែលមានសមីការ $y = 2x + 4$ ជាអាស៊ីមតូតទៅនឹងក្រាប (C) ត្រង់ $-\infty$ ។ សិក្សាទីតាំងនៃក្រាប (C) ធៀបនឹងបន្ទាត់ (d_1) ។

២ គណនាលីមីត f ត្រង់ $+\infty$ ។ ស្រាយបំភ្លឺថាបន្ទាត់ (d_2) ដែលមានសមីការ $y = 2x - 4$ ជាអាស៊ីមតូតទៅនឹងក្រាប (C) ត្រង់ $+\infty$ ។ សិក្សាទីតាំងនៃក្រាប (C) ធៀបនឹងបន្ទាត់ (d_2) ។

៣ ក គណនាដេរីវេ $f'(x)$ និងបង្ហាញថាគ្រប់ចំនួនពិត x, $f'(x) = 2\left(\dfrac{e^x-1}{e^x+1}\right)^2$ ។

ខ សិក្សាអថេរភាពនៃ f រួចសង់តារាងអថេរភាពនៃ f។ សង់ក្រាប (C) និងអាស៊ីមតូត (d_1) និង (d_2) របស់វា។

ដំណោះស្រាយ

ក្រសួងអប់រំ យុវជន និងកីឡា លេខបន្ទប់៖________

វិញ្ញាសាគណិតវិទ្យា និងវិញ្ញាសាឆ្នាំ២០០២-២០២៥ លេខតុ៖________

សម័យប្រឡង៖________________ មណ្ឌលប្រឡង៖________________

ហត្ថលេខាអនុរក្ស៖ នាមត្រកូល និងនាមខ្លួន៖________________

វិញ្ញាសាទី ១៨ ថ្ងៃខែឆ្នាំកំណើត៖________________ **អក្សរសម្ងាត់**

ហត្ថលេខា៖________________

• បេក្ខជនមិនត្រូវធ្វើសញ្ញាសម្គាល់អ្វីមួយនៅលើក្រដាសប្រឡងឡើយ។ ក្រដាសប្រឡងណាដែលមានសម្គាល់នឹងត្រូវបានពិន្ទុសូន្យ។

• បេក្ខជនមិនត្រូវចម្លងប្រធានវិញ្ញាសាដាក់លើក្រដាសប្រឡងជាដាច់ខាត។

វិញ្ញាសាទី១៨៖ គណិតវិទ្យា (ថ្នាក់វិទ្យាសាស្ត្រ) **អក្សរសម្ងាត់**

រយៈពេល៖ ១៥០នាទី

ប្រធាន៖

I (១០ពិន្ទុ) នៅក្នុងថង់មួយមានឃ្លីពណ៌សចំនួន 3 ឃ្លីពណ៌ក្រហមចំនួន 4 និងឃ្លីពណ៌ខៀវចំនួន 5។ គេចាប់យកឃ្លីចំនួន 3 ព្រមគ្នាដោយចៃដន្យចេញពីក្នុងថង់នោះ។ រកប្រូបាបនៃព្រឹត្តិការណ៍នីមួយៗខាងក្រោម៖

A : "ឃ្លីទាំង 3 ដែលចាប់បានមានពណ៌ក្រហម"

B : "យ៉ាងហោចណាស់មានឃ្លី 2 មានពណ៌ខៀវ"

C : "ឃ្លីទាំង 3 មានពណ៌ខុសៗគ្នាទាំងស្រុង"។

II (១៥ពិន្ទុ) គណនាលីមីតនៃអនុគមន៍ខាងក្រោម៖

ក. $\lim\limits_{x\to 1}\dfrac{x^2(x-2)+x^2+2x-2}{1-x}$ ខ. $\lim\limits_{x\to 0}\dfrac{-3x}{\sin 5x}$ គ. $\lim\limits_{x\to \frac{\pi}{6}}\dfrac{\sqrt{3}\sin x-\cos x}{3(\pi-6x)}$

III (១៥ពិន្ទុ) គេមានចំនួនកុំផ្លិច $z_1=2+2i$ និង $z_2=\sqrt{3}-i$។

ក. គណនាផលគុណ $z_1\times z_2$ និងផលចែក $\dfrac{z_1}{z_2}$ ជាទម្រង់ពីជគណិត។

ខ. សរសេរ $z_1\times z_2$ និង $\left(\dfrac{z_1}{z_2}\right)^2$ ជាទម្រង់ត្រីកោណមាត្រ។

គ. សរសេរ $\left(\dfrac{z_1}{z_2}\right)^3$ ជាទម្រង់ពីជគណិត។

IV (១៥ពិន្ទុ) គណនាអាំងតេក្រាលកំណត់ខាងក្រោម៖

$I=\displaystyle\int_1^3(3-2x+x^2)\,dx$

$J=\displaystyle\int_0^{\frac{\pi}{4}}\left(\sin 2x+\frac{1}{2}\sin 4x\right)dx$

$K=\displaystyle\int_2^4\left(2x-1+\frac{1}{x-1}\right)dx$

V (២៥ពិន្ទុ)

១. នៅក្នុងលំហប្រដាប់ដោយតម្រុយអរតូណរម៉ាល់ $\left(O,\vec{i},\vec{j},\vec{k}\right)$ គេមានចំណុច $A(2,1,3)$, $B(4,-1,1)$, $C(0,-1,1)$ និង $D(3,0,2)$។

ក. រកកូអរដោនេនៃវ៉ិចទ័រ $\overrightarrow{AB}$, $\overrightarrow{AC}$, $\overrightarrow{AD}$ និង $\overrightarrow{BC}$។

ខ. បង្ហាញថាចំណុច A, B និង C មិនរត់ត្រង់ជួរគ្នាទេ (មិននៅលើបន្ទាត់តែមួយ)។

គ. បង្ហាញថាវ៉ិចទ័រ $\vec{n}(0,1,-1)$ ជាវ៉ិចទ័រណរម៉ាល់នៃប្លង់ (ABC)។

២. គេមានសមីការកន្សោមមួយ៖ $(3x+4y)^2=24(xy+6)$។
បង្ហាញថាសមីការនេះជាសមីការអេលីប។ រកប្រវែងអ័ក្សធំ ប្រវែងអ័ក្សតូច កូអរដោនេនៃកំពូលទាំងពីរ រួចសង់អេលីបនេះក្នុងតម្រុយ។

VI (១០ពិន្ទុ)

១ ដោះស្រាយសមីការឌីផេរ៉ង់ស្យែល $(E): y''+3y'-4y=0$។

២ រកចម្លើយពិសេសមួយនៃសមីការឌីផេរ៉ង់ស្យែល (E) បើគេដឹងថាក្រាបខ្សែកោង (C) នៃអនុគមន៍ចម្លើយនេះកាត់តាមចំណុច $(0,3)$ ហើយបន្ទាត់ប៉ះនឹងក្រាប (C) ត្រង់ចំណុចនោះមានមេគុណប្រាប់ទិសស្មើ -3។

VII (៣៥ពិន្ទុ) គេឱ្យអនុគមន៍ f កំណត់លើចន្លោះ $(2,+\infty)$ ដោយ $f(x)=-x+3+\ln\left(\dfrac{x+2}{x-2}\right)$។ គេតាង (C) ជាក្រាបនៃអនុគមន៍នៅក្នុងប្លង់ប្រដាប់ដោយតម្រុយអរតូណរម៉ាល់ $\left(O,\vec{i},\vec{j}\right)$។

១ គណនាលីមីតនៃអនុគមន៍ f ត្រង់ 2^+ និងត្រង់ $+\infty$។

២ ស្រាយបំភ្លឺថា ចំពោះគ្រប់ $x\in(2,+\infty)$ ដេរីវេនៃអនុគមន៍ f គឺ $f'(x)=\dfrac{-x^2}{(x+2)(x-2)}$។ សិក្សាអថេរភាពនៃអនុគមន៍ f រួចសង់តារាងអថេរភាពនៃ f លើចន្លោះ $(2,+\infty)$។

៣ ក បង្ហាញថាបន្ទាត់ d_1 ដែលមានសមីការ $y=-x+3$ ជាអាស៊ីមតូតទ្រេតនៃក្រាប (C) ខាង $+\infty$។

ខ បង្ហាញថាចំពោះគ្រប់ x លើចន្លោះ $(2,+\infty)$ គេបាន $\dfrac{x+2}{x-2}>1$ រួចទាញបញ្ជាក់ពីទីតាំងធៀបរវាងក្រាប (C) និងបន្ទាត់អាស៊ីមតូត d_1។

៤ កំណត់កូអរដោនេនៃចំណុចនៅលើក្រាប (C) ដែលមានបន្ទាត់ប៉ះ d_2 មានមេគុណប្រាប់ទិសស្មើ $-\dfrac{9}{5}$ រួចសរសេរសមីការនៃបន្ទាត់ប៉ះ d_2 នោះ។

៥ សង់ក្រាប (C) បន្ទាត់អាស៊ីមតូត d_1 និងបន្ទាត់ប៉ះ d_2 ក្នុងតម្រុយតែមួយ។ (គេឱ្យតម្លៃប្រហែល $\ln 5\approx 1.6$)

ដំណោះស្រាយ

ក្រសួងអប់រំ យុវជន និងកីឡា លេខបន្ទប់៖________
វិញ្ញាសាគណិតវិទ្យា និងវិញ្ញាសាឆ្នាំ២០០២-២០២៥ លេខតុ៖________

សម័យប្រឡង៖________ មណ្ឌលប្រឡង៖________

ហត្ថលេខាអនុរក្ស៖ នាមត្រកូល និងនាមខ្លួន៖________

ថ្ងៃខែឆ្នាំកំណើត៖________

វិញ្ញាសាទី ១៩ ហត្ថលេខា៖________ | អក្សរសម្ងាត់ |

- បេក្ខជនមិនត្រូវធ្វើសញ្ញាសម្គាល់អ្វីមួយនៅលើក្រដាស់ប្រឡងឡើយ។ ក្រដាស់ប្រឡងណាដែលមានសម្គាល់នឹងត្រូវបានពិន្ទុសូន្យ។
- បេក្ខជនមិនត្រូវចម្លងប្រធានវិញ្ញាសាដាក់លើក្រដាស់ប្រឡងជាដាច់ខាត។

វិញ្ញាសាទី១៩៖ គណិតវិទ្យា (ថ្នាក់វិទ្យាសាស្ត្រ) | អក្សរសម្ងាត់ |

រយៈពេល៖ ១៥០នាទី

ប្រធាន៖

I (១៥ពិន្ទុ) គណនាលីមីត៖

ក. $\lim\limits_{x\to+\infty}\left[\sqrt{x^2+4x+5}-(x+2)\right]$

ខ. $\lim\limits_{x\to 0}\dfrac{-3x\sin 2x}{1-\cos^2 2x}$ គ. $\lim\limits_{x\to\frac{\pi}{2}}\dfrac{1-\sin x}{\sin^4 x-1}$

II (១០ពិន្ទុ) ក្នុងថង់មួយមានប៊ូល 20 ដែលគេសរសេរលេខពី 1 ដល់ 20 ។ គេចាប់យកប៊ូល 3 ចេញពីថង់ដោយចៃដន្យព្រមគ្នា។ រកប្រូបាបនៃព្រឹត្តិការណ៍៖

ក. A : ״គេចាប់បានប៊ូលទាំង 3 មានលេខសុទ្ធតែចែកដាច់នឹង 5״

ខ. B : ״គេចាប់បានប៊ូលទាំង 3 មានលេខសុទ្ធតែចែកមិនដាច់នឹង 4״

គ. C : ״គេចាប់បានប៊ូលតែមួយគត់មានលេខចែកដាច់នឹង 5״។

III (១៥ពិន្ទុ)

ក. ដោះស្រាយនៅក្នុងសំណុំចំនួនកុំផ្លិច $\mathbb{C}$ នូវសមីការ $z^2-6z+36=0$។

ខ. គេមានចំនួនកុំផ្លិច $z_1=3+3i\sqrt{3}$ និង $z_2=3-3i\sqrt{3}$។ សរសេរ $(2z_1+\overline{z_2})$ ជាទម្រង់ត្រីកោណមាត្រ និងគណនា $(2z_1+\overline{z_2})^3$។ (យើងតាង $\overline{z_2}$ ជាចំនួនកុំផ្លិចឆ្លាស់នៃ z_2)។

IV (១៥ពិន្ទុ) គណនាអាំងតេក្រាល៖

$$I=\int_0^1\left(x^2+2\right)^2dx \qquad J=\int_0^{\ln 4}(e^x-2)\,dx \qquad K=\int_0^{\frac{\pi}{4}}\left[\cos\left(2x+\frac{\pi}{4}\right)+\cos^4 x\sin x\right]dx$$

V (២៥ពិន្ទុ)

A : ក្នុងលំហប្រដាប់ដោយតម្រុយអរតូណរម៉ាល់ $\left(O,\vec{i},\vec{j},\vec{k}\right)$ គេមានចំណុច $A(1,1,1)$, $B(5,5,1)$ និង $C(5,1,5)$។

១ ក. គណនាកូអរដោនេរបស់វ៉ិចទ័រ $\overrightarrow{AB}$, $\overrightarrow{AC}$ និង $\overrightarrow{BC}$ ។

ខ. ស្រាយបំភ្លឺថាចំណុច A, B, C កំណត់បានប្លង់មួយ។

គ. បង្ហាញថាវ៉ិចទ័រ $\vec{n}=(1,-1,-1)$ ជាវ៉ិចទ័រណរម៉ាល់ទៅនឹងប្លង់ (ABC)។

ឃ. ទាញរកសមីការប្លង់របស់ (ABC)។

២ បង្ហាញថាត្រីកោណ ABC ជាត្រីកោណសម័ង្ស។

B : គេមានប៉ារ៉ាបូលដែលមានសមីការទូទៅ៖ $y^2-6y-8x+17=0$ ។ ចូរបម្លែងសមីការនេះជាទម្រង់សមីការស្តង់ដានៃប៉ារ៉ាបូល។ រកកូអរដោនេនៃកំពូល កំណុំ និងសមីការបន្ទាត់ប្រាប់ទិស រួចសង់ប៉ារ៉ាបូលនេះ។

VI (១០ពិន្ទុ) គេមានសមីការឌីផេរ៉ង់ស្យែល៖ $y''+4y'+5y=2y'+8y \quad (E)$។ ដោះស្រាយសមីការនេះ។ បង្ហាញថាអនុគមន៍ $y=3e^x-e^{-3x}$ ជាចម្លើយពិសេសនៃសមីការ (E)។

VII (៣៥ពិន្ទុ) អនុគមន៍ f កំណត់លើ $(0,+\infty)$ ដោយ $f(x)=\dfrac{x^2-3}{x}-\ln x$ ។ គេតាង (C) ជាក្រាបរបស់អនុគមន៍ f

នៅក្នុងប្លង់ប្រដាប់ដោយតម្រុយអរតូណរម៉ាល់ $\left(O,\vec{i},\vec{j}\right)$។

១ ក) បង្ហាញថាចំពោះគ្រប់ x នៅក្នុងចន្លោះ $(0,+\infty)$ គេអាចសរសេរ $f(x)=x\left(1-\frac{\ln x}{x}-\frac{3}{x^2}\right)$ និង $f(x)=\frac{1}{x}\left(x^2-x\ln x-3\right)$។

ខ) ប្រើលក្ខណៈនេះដើម្បីគណនាលីមីតនៃអនុគមន៍ f ត្រង់ 0^+ និងត្រង់ $+\infty$។

២ ក) គណនាដេរីវេ $f'(x)$ នៃអនុគមន៍ $f(x)$ និងបង្ហាញថាចំពោះគ្រប់ x លើចន្លោះ $(0,+\infty)$ កន្សោម $f'(x)$ មានសញ្ញាដូច x^2-x+3 ។

ខ) សិក្សាអថេរភាពនៃអនុគមន៍ f រួចសង់តារាងអថេរភាពរបស់វា។

៣ ក) រកសមីការបន្ទាត់ប៉ះទៅនឹងក្រាប (C) ត្រង់ចំណុច A នៅលើ (C) ដែលមានអាប់ស៊ីសស្មើ 1។

ខ) រកកូអរដោនេចំណុច B នៃក្រាប (C) ដែលបន្ទាត់ប៉ះទៅនឹង (C) ត្រង់ B ស្របទៅនឹងបន្ទាត់ $y=x$ ។

៤ សង់ក្រាប (C) និងបន្ទាត់ប៉ះត្រង់ A និងត្រង់ B។ (គេឱ្យតម្លៃប្រហែល $\ln 3=1.1$)

ដំណោះស្រាយ

ក្រសួងអប់រំ យុវជន និងកីឡា លេខបន្ទប់៖________
វិញ្ញាសាគណិតវិទ្យា និងវិញ្ញាសាឆ្នាំ២០០២-២០២៥ លេខតុ៖________

សម័យប្រឡង៖________ មណ្ឌលប្រឡង៖________

ហត្ថលេខាអនុរក្ស៖ នាមត្រកូល និងនាមខ្លួន៖________

ថ្ងៃខែឆ្នាំកំណើត៖________

វិញ្ញាសាទី ២០ ហត្ថលេខា៖________ **អក្សរសម្ងាត់**

- បេក្ខជនមិនត្រូវធ្វើសញ្ញាសម្គាល់អ្វីមួយនៅលើក្រដាស់ប្រឡងឡើយ។ ក្រដាស់ប្រឡងណាដែលមានសម្គាល់នឹងត្រូវបានពិន្ទុសូន្យ។
- បេក្ខជនមិនត្រូវចម្លងប្រធានវិញ្ញាសាដាក់លើក្រដាស់ប្រឡងជាដាច់ខាត។

វិញ្ញាសាទី២០៖ គណិតវិទ្យា (ថ្នាក់វិទ្យាសាស្ត្រ) **អក្សរសម្ងាត់**

រយៈពេល៖ ១៥០នាទី

ប្រធាន៖

I (១៥ពិន្ទុ) គណនាលីមីត៖

ក. $\lim\limits_{x\to 4}\sqrt{2x^2-7}$ ខ. $\lim\limits_{x\to\frac{\pi}{4}}\dfrac{2\sin\left(x-\frac{\pi}{4}\right)}{\left(\frac{\pi}{4}-x\right)}$ គ. $\lim\limits_{x\to+\infty}(3x-5-8\ln x)$

II (១០ពិន្ទុ) ក្នុងថង់មួយមានឃ្លីពណ៌ក្រហមចំនួន 3 ឃ្លីពណ៌ខៀវចំនួន 4 និងឃ្លីពណ៌សចំនួន 5។ គេចាប់យកឃ្លីចំនួន 3 ពីក្នុងថង់ដោយចៃដន្យព្រមគ្នា។ គណនាប្រូបាបនៃព្រឹត្តិការណ៍ខាងក្រោម៖

ក. ឃ្លីទាំង 3 មានពណ៌សសុទ្ធ ខ. ឃ្លីទាំង 3 មានពណ៌ខុសៗគ្នា។

III (១៥ពិន្ទុ)

ក. គេមានចំនួនកុំផ្លិច $z_1=\sqrt{3}+i\sqrt{3}$។ រក $\overline{z_1}$ ($\overline{z_1}$ ជាចំនួនកុំផ្លិចឆ្លាស់នៃ z_1)។

ខ. រកម៉ូឌុល និង អាគុយម៉ង់នៃចំនួនកុំផ្លិច z_1 ។ សរសេរ z_1 ជាទម្រង់ត្រីកោណមាត្រ។

គ. បង្ហាញថា $\overline{z_1}$ ជាឫសរបស់សមីការ $z^2=2\left(z\sqrt{3}-3\right)$ ។

IV (១៥ពិន្ទុ) គណនាអាំងតេក្រាល៖

$I=\int_0^1\left(6x^2-4x+2\right)dx \qquad J=\int_0^1\left(\dfrac{e^x}{e^x+2}\right)dx \qquad K=\int_0^{\frac{\pi}{2}}\left(\cos^3 x\sin x\right)dx$

V (២៥ពិន្ទុ)

១. ក្នុងលំហប្រដាប់ដោយតម្រុយអរតូណរម៉ាល់ $\left(O,\vec{i},\vec{j},\vec{k}\right)$ គេមានចំណុច៖ $A(1,0,1)$, $B(3,2,2)$, $C(1,6,-2)$ និង $D(-1,4,-3)$ ។

រកវ៉ិចទ័រ $\overrightarrow{AB}$, $\overrightarrow{BC}$, $\overrightarrow{CD}$ និង $\overrightarrow{AD}$ រួចបង្ហាញថាចតុកោណ $ABCD$ ជាចតុកោណកែងតែមិនមែនជាការេ។

២. គេមានសមីការ $16y^2=25(4-x)(4+x)$។ បង្ហាញថា សមីការនេះជាអេលីប។

រកប្រវែងអ័ក្សធំ អ័ក្សតូច កូអរដោនេកំពូលទាំងពីរ និង កូអរដោនេកំណុំទាំងពីររបស់អេលីប ។ សង់អេលីបនេះ ។

VI (១០ពិន្ទុ) គេមានសមីការឌីផេរ៉ង់ស្យែល $(E): y''=-9y$ ។

ក. បង្ហាញថា $y=\lambda\cos 3x+\mu\sin 3x$ ដែល λ , μ ជាចំនួនពិត ជាចម្លើយរបស់សមីការឌីផេរ៉ង់ស្យែល (E) ។

ខ. រកចម្លើយពិសេសរបស់សមីការឌីផេរ៉ង់ស្យែល (E) ដែល $y''(0)=9$ និង $y'(0)=0$ ។

VII (៣៥ពិន្ទុ) គេមានអនុគមន៍ f ដែល $f(x)=x-5+\dfrac{2(x+1)}{e^x}$ ។ យើងតាង (C) ជាក្រាបរបស់អនុគមន៍ f នៅក្នុងប្លង់ប្រដាប់ដោយតម្រុយអរតូណរម៉ាល់ $\left(O,\vec{i},\vec{j}\right)$ ។

១. រកដែនកំណត់នៃអនុគមន៍ f ។ គណនា $\lim\limits_{x\to+\infty}f(x)$ និង $\lim\limits_{x\to-\infty}f(x)$ (គេដឹងថា $\lim\limits_{x\to+\infty}\dfrac{x}{e^x}=0$)។

② បង្ហាញថាបន្ទាត់ (D) ដែលមានសមីការ $y = x - 5$ ជាអាស៊ីមតូតទ្រេតនៃ (C) ត្រង់ $+\infty$។ បញ្ជាក់ទីតាំង (C) ធៀបនឹងបន្ទាត់ (D) ។

③ យើងតាង $f'(x)$ ជាដេរីវេនៃ $f(x)$ បង្ហាញថា $f'(x) = \dfrac{e^x - 2x}{e^x}$ ។ គេដឹងថាគ្រប់ $x \in \mathbb{R}, e^x - 2x > 0$ ។ ប្រើលទ្ធផលនេះដើម្បីទាញយកការសិក្សាអថេរភាពនៃអនុគមន៍ f ។

④ បង្ហាញថាបន្ទាត់ប៉ះ (Δ) ទៅនឹង (C) ត្រង់ចំណុចដែលមានអាប់ស៊ីស 0 ស្របនឹងបន្ទាត់ (D) ។ សង់បន្ទាត់ (D) , (Δ) និង ក្រាប (C) ។

ដំណោះស្រាយ

ក្រសួងអប់រំ យុវជន និងកីឡា

វិញ្ញាសាគណិតវិទ្យា នឹងវិញ្ញាសាឆ្នាំ២០០២-២០២៥

លេខបន្ទប់៖________

លេខតុ៖________

សម័យប្រឡង៖______________________ មណ្ឌលប្រឡង៖______________________

ហត្ថលេខាអនុរក្ស៖ នាមត្រកូល និងនាមខ្លួន៖______________________

ថ្ងៃខែឆ្នាំកំណើត៖______________________

វិញ្ញាសាទី ២១

ហត្ថលេខា៖______________________

អក្សរសម្ងាត់

- បេក្ខជនមិនត្រូវធ្វើសញ្ញាសម្គាល់អ្វីមួយនៅលើក្រដាស់ប្រឡងឡើយ។ ក្រដាស់ប្រឡងណាដែលមានសម្គាល់នឹងត្រូវបានពិន្ទុសូន្យ។
- បេក្ខជនមិនត្រូវចម្លងប្រធានវិញ្ញាសាដាក់លើក្រដាស់ប្រឡងជាដាច់ខាត។

វិញ្ញាសាទី២១៖ គណិតវិទ្យា (ថ្នាក់វិទ្យាសាស្ត្រ)

រយៈពេល៖ ១៥០នាទី

អក្សរសម្ងាត់

ប្រធាន៖

I (១០ពិន្ទុ) គណនាលីមីត៖

ក. $\lim\limits_{x\to 0}\dfrac{e^{2x}+1}{3e^{2x}}$ ខ. $\lim\limits_{x\to 2}\dfrac{\sqrt{x+2}-2}{\sqrt{2x}-2}$ គ. $\lim\limits_{x\to \frac{\pi}{4}}\dfrac{\sqrt{2}\left(\frac{\pi}{4}-x\right)}{\sin\left(x-\frac{\pi}{4}\right)}$

II (១៥ពិន្ទុ) គណនាអាំងតេក្រាល៖

ក. $I=\displaystyle\int_0^1 (3-2x+x^2)\,dx$ ខ. $J=\displaystyle\int_0^{\frac{\pi}{6}}\left(\frac{\cos 6x-\cos 2x}{2}\right)dx$

គ. គេមាន $f(x)=\dfrac{x^2-2}{2x-3}$ បង្ហាញថា $f(x)=\dfrac{x}{2}+\dfrac{3}{4}+\dfrac{1}{4(2x-3)}$ ។ គណនា $K=\displaystyle\int_0^1 f(x)\,dx$ ។

III (១៥ពិន្ទុ) គេមានចំនួនកុំផ្លិច $z_1=i(2+3i)(1+2i)^2$ ។

ក. សរសេរ z_1 ជាទម្រង់ពីជគណិត រួចរក $\overline{z_1}$ ដែលជាចំនួនកុំផ្លិចឆ្លាស់នៃ z_1 ។

ខ. សរសេរ $z_2=z_1+22$ ជាទម្រង់ត្រីកោណមាត្រ។ គណនា៖ z_2^4 និង z_2^6 ។

IV (១០ពិន្ទុ) ក្នុងគ្លីនិកមួយមានគ្រូពេទ្យនារី 8 នាក់ និងគ្រូពេទ្យបុរស 6 នាក់។ គេរៀបចំជាក្រុមគ្រូពេទ្យបង្គោលមួយក្រុមមានគ្នា 4 នាក់ដោយចៃដន្យដើម្បីចុះយុទ្ធនាការ។ រកប្រូបាបនៃព្រឹត្តិការណ៍ខាងក្រោម៖

ក. A : "ក្រុមគ្រូពេទ្យដែលរៀបចំមានសមាជិកទាំង 4 នាក់សុទ្ធតែជានារី"

ខ. B : "ក្រុមគ្រូពេទ្យដែលរៀបចំមានសមាជិក 50% ជានារី" ។

V (២៥ពិន្ទុ)

១. ក្នុងលំហប្រដាប់ដោយតម្រុយអរតូណរម៉ាល់ $\left(O,\vec{i},\vec{j},\vec{k}\right)$ គេមានចំណុច $M(1,0,1)$, $N(2,1,2)$, $P(1,3,-2)$ និង $Q(-1,1,0)$ ។

ក. រកវ៉ិចទ័រ $\overrightarrow{MN},\overrightarrow{NP},\overrightarrow{NQ},\overrightarrow{PQ}$ និងរកប្រវែងវ៉ិចទ័រទាំងបួននេះ។

ខ. បង្ហាញថាត្រីកោណ NPQ ជាត្រីកោណកែងត្រង់ Q និងរកផ្ទៃក្រឡារបស់ត្រីកោណនេះ។

២. រកកូអរដោនេកំពូល កំណុំ និងសមីការបន្ទាត់ប្រាប់ទិសរបស់ប៉ារ៉ាបូលដែលមានសមីការ $(y+3)^2=-4(x-1)$ ។ សង់ប៉ារ៉ាបូលនេះ ។

VI (១០ពិន្ទុ) គេមានសមីការឌីផេរ៉ង់ស្យែល $(E): y'+y=2(x+2)e^{-x}$។

ក. បង្ហាញថាអនុគមន៍ y_0 កំណត់លើ $\mathbb{R}$ ដោយ $y_0(x)=(x^2+4x)e^{-x}$ ជាចម្លើយមួយនៃសមីការឌីផេរ៉ង់ស្យែល (E)។

ខ. ដោះស្រាយសមីការឌីផេរ៉ង់ស្យែល $(E'): y'+y=0$ ដែលផ្ទៀងផ្ទាត់លក្ខខណ្ឌ $y(0)=e^2$។

VII (៤០ពិន្ទុ)

១. គេមានអនុគមន៍ f កំណត់ដោយ $f(x)=2x-\ln(1+2x)$ ។ យើងតាងដោយ (C) ជាក្រាបរបស់ f ។

ក. រកដែនកំណត់ D នៃអនុគមន៍ f ។ គណនា $\lim\limits_{x\to -\frac{1}{2}^+} f(x)$ និង $\lim\limits_{x\to +\infty} f(x)$ ។

ខ. សិក្សាអថេរភាពរបស់អនុគមន៍ $f(x)$ ដោយភ្ជាប់តារាងអថេរភាពនៅលើ D និងបញ្ជាក់សញ្ញានៃ $f(x)$ លើ D ។

២. គេចង់សិក្សាទីតាំងរបស់ក្រាប (C) នៃ f ធៀបទៅនឹងក្រាប (P) ដែលមានសមីការ $y = 2x^2$ ។

ក. ក្នុងន័យនេះគេបង្កើតអនុគមន៍ g កំណត់លើ D ដែលជាដែនកំណត់របស់ f ដោយ $g(x) = f(x) - 2x^2$ ។ សិក្សាអថេរភាពនៃអនុគមន៍ g និងទាញយកសញ្ញានៃ $g(x)$ កាលណា x រត់នៅលើ D ។ សិក្សាទីតាំងនៃក្រាប (C) ធៀបនឹងក្រាប (P) ។

ខ. សង់ក្រាប (C) និងក្រាប (P) ក្នុងតម្រុយអរតូណរម៉ាល់ $\left(O, \vec{i}, \vec{j}\right)$ តែមួយ។

ដំណោះស្រាយ

ក្រសួងអប់រំ យុវជន និងកីឡា លេខបន្ទប់៖__________

វិញ្ញាសាគណិតវិទ្យា នឹងវិញ្ញាសាឆ្នាំ២០០២-២០២៥ លេខតុ៖__________

សម័យប្រឡង៖______________________________ មណ្ឌលប្រឡង៖______________________________

ហត្ថលេខាអនុរក្ស៖ នាមត្រកូល និងនាមខ្លួន៖______________________________

ថ្ងៃខែឆ្នាំកំណើត៖______________________________

វិញ្ញាសាទី ២២ ហត្ថលេខា៖______________________________ | អក្សរសម្ងាត់ |

- បេក្ខជនមិនត្រូវធ្វើសញ្ញាសម្គាល់អ្វីមួយនៅលើក្រដាស់ប្រឡងឡើយ។ ក្រដាស់ប្រឡងណាដែលមានសម្គាល់នឹងត្រូវបានពិន្ទុសូន្យ។
- បេក្ខជនមិនត្រូវចម្លងប្រធានវិញ្ញាសាដាក់លើក្រដាស់ប្រឡងជាដាច់ខាត។

វិញ្ញាសាទី២២៖ គណិតវិទ្យា (ថ្នាក់វិទ្យាសាស្ត្រ) | អក្សរសម្ងាត់ |

រយៈពេល៖ ១៥០នាទី

ប្រធាន៖

I (១០ពិន្ទុ) គណនាលីមីតខាងក្រោម៖

ក. $\lim\limits_{x\to+\infty}\left[x\ln\left(1+\frac{2}{x}\right)\right]$ (គេដឹងថា $\lim\limits_{X\to0}\frac{\ln(1+X)}{X}=1$)

ខ. $\lim\limits_{x\to\frac{\pi}{2}}\frac{1-\sin^2 x}{2-2\sin x}$

គ. $\lim\limits_{x\to2}\frac{x^3-8}{12(\sqrt{x+7}-3)}$

II (១៥ពិន្ទុ) គណនាអាំងតេក្រាលខាងក្រោម៖

ក. $I=\int_0^2(x-2)(x+4)\,dx$

ខ. $J=\int_0^{\frac{\pi}{2}}\cos^3 x\sin x\,dx$

គ. $K=\int_1^2\left(\frac{4}{2x-1}\right)dx$

III (១៥ពិន្ទុ) ដោះស្រាយក្នុងសំណុំចំនួនកុំផ្លិចនូវសមីការ $z^2-4z+16=0$។ សរសេរចម្លើយទាំងពីរដោយតាងជា z_1 និង z_2 ជាទម្រង់ត្រីកោណមាត្រ។

IV (១០ពិន្ទុ) អ្នកលក់ប៊ិចម្នាក់ គាត់មានប៊ិចចំនួន 30 ដើម ដែលក្នុងនោះមានប៊ិច 4 ដើមខូច (សរសេរមិនចេញ)។ គេចាប់យកប៊ិចមួយដើមក្នុងចំណោម 30 ដើមនោះដោយចៃដន្យ។

១. រកប្រូបាបនៃព្រឹត្តិការណ៍ A : "ប៊ិចដែលចាប់បានជាប៊ិចល្អ"។

២. អ្នកទិញម្នាក់ចាប់យកដោយមិនបានផ្ទៀងផ្ទាត់ ហើយគាត់ចង់បានដាច់ខាតប៊ិចល្អចំនួន 5 ដើម។ តើគាត់ត្រូវទិញប៊ិចយ៉ាងតិចចំនួនប៉ុន្មានដើមទើបប្រាកដថាបានប៊ិចល្អចំនួន 5?

៣. គេចាប់យកប៊ិច 2 ដើមម្តងដោយចៃដន្យក្នុងចំណោមប៊ិចទាំង 30។ រកប្រូបាបនៃព្រឹត្តិការណ៍ B : "ប៊ិចទាំងពីរដែលចាប់បានសុទ្ធតែជាប៊ិចល្អ"។

V (២៥ពិន្ទុ)

១. ក្នុងលំហប្រដាប់ដោយតម្រុយអរតូណរម៉ាល់ $\left(O,\vec{i},\vec{j},\vec{k}\right)$ គេមានចំណុច $A(0,0,0)$, $B(1,0,2)$, $C(3,1,4)$ និង $D(0,4,1)$។

ក. បង្ហាញថាចំណុច A, B និង C មិនស្ថិតនៅលើបន្ទាត់តែមួយ។

ខ. បង្ហាញថាត្រីកោណ BCD ជាត្រីកោណកែង រួចរកផ្ទៃក្រឡារបស់ត្រីកោណនេះ។

២. គេឱ្យសមីការ $40(xy+10)-(4x+5y)^2=0$។

ក. បង្ហាញថាសមីការនេះជាសមីការអេលីប។

ខ. ចូររកប្រវែងអ័ក្សតូច អ័ក្សធំ និងកូអរដោនេនៃកំពូលទាំងពីរ រួចសង់អេលីបនេះ។

VI (១០ពិន្ទុ)

ក. ដោះស្រាយសមីការឌីផេរ៉ង់ស្យែល $(E) : 2y''=8y-6y'$។

ខ. រកចម្លើយពិសេសមួយរបស់សមីការឌីផេរ៉ង់ស្យែល (E) ដែលផ្ទៀងផ្ទាត់លក្ខខណ្ឌ $y(0) = 1$ និង $y'(1) = e$។

VII (៤០ពិន្ទុ) គេមានអនុគមន៍ f កំណត់លើសំណុំចំនួនពិត $\mathbb{R}$ ដោយ $f(x) = 5 - x - 3e^{-x}$ ។ គេតាង (C) ជាក្រាបរបស់ f ក្នុងប្លង់កូអរដោនេ។

ផ្នែក : $A.$

1. ផ្ទៀងផ្ទាត់ថាចំពោះគ្រប់ចំនួនពិត x, $f(x) = \dfrac{5e^x - xe^x - 3}{e^x}$។
   គណនាលីមីត $\lim\limits_{x\to+\infty} f(x)$ និង $\lim\limits_{x\to-\infty} f(x)$ ដោយដឹងថា $\lim\limits_{x\to-\infty} xe^x = 0$។
2. បង្ហាញថាបន្ទាត់ (D) ដែលមានសមីការ $y = -x + 5$ ជាអាស៊ីមតូតទ្រេតនៃក្រាប (C)។
3. សិក្សាទីតាំងធៀបរវាងក្រាប (C) និងបន្ទាត់អាស៊ីមតូត (D)។

ផ្នែក: $B.$

1. គណនាដេរីវេ $f'(x)$ នៃអនុគមន៍ $f(x)$។ សិក្សាអថេរភាពនៃ f និងគណនាតម្លៃអតិបរមារបស់ f។
2. A ជាចំណុចនៃក្រាប (C) ដែលមានអាប់ស៊ីស $x = 0$។ រកសមីការបន្ទាត់ប៉ះ (T) ទៅនឹងក្រាប (C) ត្រង់ចំណុច A។
3. បង្ហាញថាសមីការ $f(x) = 0$ មានឫសតែមួយគត់ β នៅក្នុងចន្លោះ $[-1, 0]$។
4. សង់បន្ទាត់ប៉ះ (T) អាស៊ីមតូត (D) និងក្រាប (C)។

ដំណោះស្រាយ

ក្រសួងអប់រំ យុវជន និងកីឡា លេខបន្ទប់៖________

វិញ្ញាសាគណិតវិទ្យា និងវិញ្ញាសាឆ្នាំ២០០២-២០២៥ លេខតុ៖________

សម័យប្រឡង៖________ មណ្ឌលប្រឡង៖________

ហត្ថលេខាអនុរក្ស៖ នាមត្រកូល និងនាមខ្លួន៖________

ថ្ងៃខែឆ្នាំកំណើត៖________

វិញ្ញាសាទី ២៣ ហត្ថលេខា៖________ **អក្សរសម្ងាត់**

• បេក្ខជនមិនត្រូវធ្វើសញ្ញាសម្គាល់អ្វីមួយនៅលើក្រដាសប្រឡងឡើយ។ ក្រដាសប្រឡងណាដែលមានសម្គាល់នឹងត្រូវបានពិន្ទុសូន្យ។

• បេក្ខជនមិនត្រូវចម្លងប្រធានវិញ្ញាសាដាក់លើក្រដាសប្រឡងជាដាច់ខាត។

វិញ្ញាសាទី២៣៖ គណិតវិទ្យា (ថ្នាក់វិទ្យាសាស្ត្រ) **អក្សរសម្ងាត់**

រយៈពេល៖ ១៥០នាទី

ប្រធាន៖

I (១៥ពិន្ទុ) គណនាលីមីត៖

ក. $\lim\limits_{x\to 0}(e^{2x}-2x+5)$

គ. $\lim\limits_{x\to -\infty}\left(2x+\sqrt{4x^2+5}\right)$

ខ. រកតម្លៃ a បើ $\lim\limits_{x\to+\infty}\dfrac{6x^2-5x+2}{ax^2+3}=2$

ឃ. $\lim\limits_{x\to 0}\dfrac{1-\cos 2x}{x^2}$

II (១៥ពិន្ទុ) ក្នុងប្រអប់មួយមានប៊ិចសរុបចំនួន 20 ដើម ដែលក្នុងនោះមានប៊ិចពណ៌ក្រហម 4 ដើម ពណ៌ខៀវ 6 ដើម និងពណ៌ខ្មៅ 10 ដើម។ គេជ្រើសរើសយកប៊ិចចំនួន 3 ដើមដោយចៃដន្យព្រមគ្នា។ រកប្រូបាបនៃព្រឹត្តិការណ៍ខាងក្រោម៖

ក. A : "ប៊ិចទាំង 3 ដើម សុទ្ធតែជាពណ៌ក្រហម"

ខ. B : "ប៊ិចទាំង 3 ដើម សុទ្ធតែជាពណ៌ខៀវ ឬពណ៌ខ្មៅ"

គ. C : "ប៊ិចទាំង 3 ដើម មានពណ៌ខុសៗគ្នាទាំងអស់ (មានក្រហម១ ខៀវ១ ខ្មៅ១)"។

III (១៥ពិន្ទុ) គណនាអាំងតេក្រាល៖

ក. $I=\int_1^e\left[2x-3+\dfrac{1}{x}\right]dx$

គ. $K=\int_0^1(x^2+2)^4x\,dx$

ខ. $J=\int_0^1\dfrac{2x+2}{x^2+2x+3}dx$

ឃ. $L=\int_0^{\frac{\pi}{4}}(2\sin 2x)\,dx$

IV (១៥ពិន្ទុ) នៅក្នុងសំណុំនៃចំនួនកុំផ្លិច $\mathbb{C}$៖

ក. ដោះស្រាយសមីការ $z-2\overline{z}=-3+6i$ ។ គណនា i^{2026} ។

ខ. គេមាន $z_1=1-i$ និង $z_2=2+4i$ ។ គណនា $z=z_1+z_2$ រួចសរសេរ z ជាទម្រង់ត្រីកោណមាត្រ ។

V (១០ពិន្ទុ) គេមានសមីការឌីផេរ៉ង់ស្យែល $(E): y'+2y=2e^{-x}$ ។

ក. បង្ហាញថាអនុគមន៍ u កំណត់លើ $\mathbb{R}$ ដោយ $u(x)=2e^{-x}$ ជាចម្លើយមួយរបស់សមីការ (E)។

ខ. គេមានសមីការឌីផេរ៉ង់ស្យែល $(E'): y'+2y=0$ ។ ដោះស្រាយសមីការ (E') ។

គ. ទាញរកចម្លើយទូទៅរបស់សមីការឌីផេរ៉ង់ស្យែល (E) ។

VI (២០ពិន្ទុ)

១. ក្នុងលំហប្រដាប់ដោយតម្រុយអរតូណរម៉ាល់ $\left(O,\vec{i},\vec{j},\vec{k}\right)$ គេមានចំណុច $A(1,2,0)$, $B(4,2,0)$ និង $C(1,5,0)$ ។ រកកូអរដោនេនៃវ៉ិចទ័រ $\vec{AB}$ និង $\vec{AC}$ ។ បង្ហាញថាត្រីកោណ ABC ជាត្រីកោណកែងសមបាត និងរកផ្ទៃក្រឡារបស់វា ។

២. គេឱ្យសមីការអ៊ីពែបូល $\dfrac{x^2}{9}-\dfrac{y^2}{16}=1$ ។ កំណត់កូអរដោនេនៃកំពូលទាំងពីរ កំណុំទាំងពីរ និងសមីការអាស៊ីមតូតទាំងពីរនៃអ៊ីពែបូលនេះ រួចចូរសង់អ៊ីពែបូល។

VII (៣០ពិន្ទុ) គេមានអនុគមន៍ f កំណត់លើចន្លោះ $(0,+\infty)$ ដោយ $f(x)=\ln(x+2)-\ln x-x+3$ ។ គេតាង (C) ជាក្រាបរបស់វានៅក្នុងប្លង់ប្រដាប់ដោយតម្រុយអរតូណរម៉ាល់ $\left(O,\vec{i},\vec{j}\right)$ ។

ក. បង្ហាញថា $f(x)=3-x+\ln\left(\dfrac{x+2}{x}\right)$ ។ គណនាលីមីតនៃ $f(x)$ ត្រង់ 0^+ និងត្រង់ $+\infty$ ។

ខ. បង្ហាញថានៅលើចន្លោះ $(0,+\infty)$ ដេរីវេនៃអនុគមន៍ f គឺ $f'(x)=\dfrac{-(x^2+2x+2)}{x(x+2)}$ ។
សង់តារាងអថេរភាពនៃ f (មិនបាច់បញ្ជាក់សញ្ញាដេរីវេវែងឆ្ងាយទេ)។

គ. បង្ហាញថាបន្ទាត់ (d) ដែលមានសមីការ $y=-x+3$ ជាអាស៊ីមតូតទ្រេតនៃក្រាប (C) ។

ឃ. សង់បន្ទាត់ (d) និងក្រាប (C) ក្នុងតម្រុយតែមួយ។

ដំណោះស្រាយ

ក្រសួងអប់រំ យុវជន និងកីឡា លេខបន្ទប់៖________

វិញ្ញាសាគណិតវិទ្យា នឹងវិញ្ញាសាឆ្នាំ២០០២-២០២៥ លេខតុ៖________

សម័យប្រឡង៖________________ មណ្ឌលប្រឡង៖________________

ហត្ថលេខាអនុរក្ស៖ នាមត្រកូល និងនាមខ្លួន៖________________

វិញ្ញាសាទី ២៤ ថ្ងៃខែឆ្នាំកំណើត៖________________

ហត្ថលេខា៖________________ | អក្សរសម្ងាត់ |

- បេក្ខជនមិនត្រូវធ្វើសញ្ញាសម្គាល់អ្វីមួយនៅលើក្រដាស់ប្រឡងឡើយ។ ក្រដាស់ប្រឡងណាដែលមានសម្គាល់នឹងត្រូវបានពិន្ទុសូន្យ។
- បេក្ខជនមិនត្រូវចម្លងប្រធានវិញ្ញាសាដាក់លើក្រដាស់ប្រឡងជាដាច់ខាត។

វិញ្ញាសាទី២៤៖ គណិតវិទ្យា (ថ្នាក់វិទ្យាសាស្ត្រ) | អក្សរសម្ងាត់ |

រយៈពេល៖ ១៥០នាទី

ប្រធាន៖

I (១៥ពិន្ទុ) គណនាលីមីត៖

ក. $\lim\limits_{x\to 2}\left(\sqrt{x^2+5}+2x\right)$

ខ. $\lim\limits_{x\to 0}\dfrac{e^{3x}-1}{e^{x}-1}$

គ. $\lim\limits_{x\to 1}\dfrac{3-\sqrt{x+8}}{x^2-1}$

ឃ. $\lim\limits_{x\to \frac{\pi}{6}}\dfrac{x-\frac{\pi}{6}}{2\sin x-1}$

II (១០ពិន្ទុ) ក្នុងប្រអប់មួយមានឃ្លីទាំងអស់ចំនួន 30 គ្រាប់ ដែលក្នុងនោះមានឃ្លីពណ៌លឿង 18 គ្រាប់ និងឃ្លីពណ៌បៃតង 12 គ្រាប់។ គេចាប់យកកូនឃ្លីពីរព្រមគ្នាពីក្នុងប្រអប់ដោយចៃដន្យ។ គណនាប្រូបាបនៃព្រឹត្តិការណ៍ខាងក្រោម៖

A A : "កូនឃ្លីទាំងពីរដែលចាប់បានមានពណ៌ខុសគ្នា"

B B : "កូនឃ្លីទាំងពីរដែលចាប់បានមានពណ៌បៃតង"

C C : "កូនឃ្លីទាំងពីរដែលចាប់បានមានពណ៌ដូចគ្នា"។

III (១៥ពិន្ទុ) គេមានចំនួនកុំផ្លិច $z_1=1+i\sqrt{3}$, $z_2=2(1+i)$ និង $Z=\dfrac{z_1^4}{z_2^4}$។ រកម៉ូឌុល និងអាគុយម៉ង់នៃ z_1, z_2 និង Z រួចសរសេរ z_1, z_2 និង Z ជាទម្រង់ត្រីកោណមាត្រ។ សរសេរ Z ជាទម្រង់ពីជគណិត។

IV (១៥ពិន្ទុ) គណនាអាំងតេក្រាល $I=\int_0^1(3x^2+x-2)\,dx$។ គណនាអាំងតេក្រាល $J_1=\int_0^2\dfrac{x\,dx}{x^2+1}$។ គេមាន $J_2=\int_0^2\dfrac{x^3}{x^2+1}\,dx$។ គណនា J_1+J_2 និងទាញយកតម្លៃនៃ J_2។ គណនាអាំងតេក្រាល $K=\int_0^{\frac{\pi}{2}}(\sin^2 x\cos^2 x)\,dx$។

V (១០ពិន្ទុ)

ក. ដោះស្រាយសមីការឌីផេរ៉ង់ស្យែល $(E): y''+3y'+2y=0$។

ខ. រកចម្លើយពិសេសមួយនៃសមីការឌីផេរ៉ង់ស្យែល (E) ដែលផ្ទៀងផ្ទាត់លក្ខខណ្ឌ $y(0)=2$ និង $y'(0)=-1$។

VI (២០ពិន្ទុ)

A ក្នុងលំហប្រដាប់ដោយតម្រុយអរតូណរម៉ាល់ $\left(O,\vec{i},\vec{j},\vec{k}\right)$ គេមានចំណុច $A(1,2,3)$, $B(3,2,1)$ និង $C(1,2,1)$។

១. គណនាកូអរដោនេនៃវ៉ិចទ័រ $\overrightarrow{AB}, \overrightarrow{AC}$ និង $\overrightarrow{BC}$។

២. បង្ហាញថាត្រីកោណ ABC កែងត្រង់ C និងរកផ្ទៃក្រឡារបស់ត្រីកោណនេះ។

B ប៉ារ៉ាបូលមួយមានកំពូលនៅគល់តម្រុយ $O(0,0)$ និងមានអ័ក្សស៊ីមេទ្រីជាអ័ក្សអរដោនេ (Oy)។ រកសមីការស្តង់ដានៃប៉ារ៉ាបូលនេះ បើវាកាត់តាមចំណុច $M(4,2)$។ រកកូអរដោនេនៃចំណុចកំណុំ F និងសមីការបន្ទាត់ប្រាប់ទិស។

VII (៤០ពិន្ទុ) គេមានអនុគមន៍ g កំណត់លើចន្លោះ $(-2,2)$ ដោយ $g(x)=\ln\left(\dfrac{2+x}{2-x}\right)$។

១. បង្ហាញថា $g(x)$ ជាអនុគមន៍សេស។ (គេដឹងថា g ជាអនុគមន៍សេសលុះត្រាតែ $g(-x)=-g(x)$)។

២. គណនាលីមីតនៃអនុគមន៍ $g(x)$ ត្រង់ -2^{+} និង 2^{-}។ សិក្សាអថេរភាពនៃ $g(x)$ រួចសង់តារាងអថេរភាព។

៣. នៅក្នុងប្លង់កូអរដោនេប្រដាប់ដោយតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j})$ តាង (C) ជាក្រាបនៃអនុគមន៍ $g(x)$។ កំណត់សមីការ

បន្ទាត់ប៉ះ (T) ទៅនឹងក្រាប (C) ត្រង់ចំណុចដែលមានអាប់ស៊ីស $x=0$។ សង់ក្រាប (C) និងបន្ទាត់ប៉ះ (T)។

៤ ក. គណនាដេរីវេនៃអនុគមន៍ $h(x)$ ដែល $h(x)=x\cdot g(x)$។

ខ. រកផ្ទៃក្រឡានៃផ្ទៃកប្លង់ខណ្ឌដោយក្រាប (C) អ័ក្សអាប់ស៊ីស និងបន្ទាត់ឈរដែលមានសមីការ $x=0$ និង $x=1$។

ដំណោះស្រាយ